**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## នីតិវិធី នៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



២៨៧

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងកំណត់យន្តការដឹកនាំនិងគ្រប់គ្រងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ នៅក្នុងស្ថាប័នអនុវត្តលទ្ធកម្ម ដើម្បីធានាឱ្យការដឹកនាំ ការគ្រប់គ្រង និងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ សម្រាប់ការទិញ ការសាងសង់ ការផ្គត់ផ្គង់ ការជួលសេវាកម្ម និងការជួលសេវាទីប្រឹក្សា ប្រព្រឹត្តទៅដោយរលូន ប្រកបដោយតម្លាភាព គណនេយ្យភាព យុត្តិធម៌ ប្រសិទ្ធភាព គុណភាព សមភាព ការសន្សំសំចៃ និងភាពទាន់ពេលវេលា ព្រមទាំងធានាបាននូវប្រព័ន្ធលទ្ធកម្មសាធារណៈឯកភាពមួយនៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់ក្របខណ្ឌគតិយុត្ត សម្រាប់ការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម នៅគ្រប់ស្ថាប័នអនុវត្តលទ្ធកម្ម ក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះគ្រប់ស្ថាប័នអនុវត្តលទ្ធកម្ម ដែលរួមមាន ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល អង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត និងដៃគូឯកជនសាធារណៈ ដែលអនុវត្តកិច្ចលទ្ធកម្មសាធារណៈ នៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤.-**

និយមន័យនៃបច្ចេកសព្ទដែលប្រើប្រាស់ក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់ដោយសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២។

## ជំពូកទី២

## គណៈកម្មាធិការលទ្ធកម្ម

**មាត្រា៥.-**

គ្រប់ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវបង្កើតគណៈកម្មាធិការលទ្ធកម្មមួយ ដោយប្រកាស សេចក្តីសម្រេច ឬដីកា ដើម្បីគ្រប់គ្រង និងដឹកនាំការអនុវត្តកិច្ចលទ្ធកម្មសាធារណៈឱ្យស្របតាមគោលការណ៍ វិធាន វិធីសាស្ត្រ និងនីតិវិធី ដែលត្រូវបានកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

សម្រាប់សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត ការបង្កើតគណៈកម្មាធិការលទ្ធកម្ម ត្រូវធ្វើឡើងដោយអង្គភាពប្រតិបត្តិ ដោយមានការអនុម័តយល់ព្រមពីក្រុមប្រឹក្សាភិបាល។

**មាត្រា៦.-**

គណៈកម្មាធិការលទ្ធកម្មមានសមាសភាពដូចខាងក្រោម÷

- ប្រធានស្ថាប័នអនុវត្តលទ្ធកម្ម ប្រធាន
- អនុប្រធានឬថ្នាក់ដឹកនាំ នៃស្ថាប័នអនុវត្តលទ្ធកម្ម ០១ ឬ០២រូប អនុប្រធាន

- ប្រធាន និង/ឬ អនុប្រធាន នៃអង្គភាពទទួលបន្ទុកកិច្ចការហិរញ្ញវត្ថុ ដែលអាចជាអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន នាយកដ្ឋាន ឬ ការិយាល័យ ០១ ឬ ០២រូប សមាជិក
- ប្រធានអង្គភាពលទ្ធកម្ម លេខាធិការ។

គណៈកម្មាធិការលទ្ធកម្ម អាចមានតំណាងអង្គភាពបច្ចេកទេសពាក់ព័ន្ធមុខសញ្ញាលទ្ធកម្ម ជាសមាជិកចំពោះកិច្ចដោយពេញច្បាប់ អាស្រ័យទៅតាមគម្រោងនីមួយៗ។

សមាសភាពជាក់ស្តែង នៃគណៈកម្មាធិការលទ្ធកម្ម ត្រូវកំណត់ដោយប្រកាស សេចក្តីសម្រេច ឬដីការបស់ប្រធានស្ថាប័នអនុវត្តលទ្ធកម្ម។

**មាត្រា៧.-**

ប្រធានស្ថាប័នអនុវត្តលទ្ធកម្ម អាចអញ្ជើញមន្ត្រីជំនាញក្នុងស្ថាប័នរបស់ខ្លួន ឬមន្ត្រីជំនាញពីស្ថាប័នផ្សេង ក្នុងករណីពុំមានមន្ត្រីជំនាញក្នុងស្ថាប័នរបស់ខ្លួន ដើម្បីផ្តល់យោបល់ជំនាញពាក់ព័ន្ធ។

**មាត្រា៨.-**

សមាសភាពគណៈកម្មាធិការលទ្ធកម្មទាំងអស់ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន កិច្ចប្រជុំអាចប្រព្រឹត្តទៅតាមការអញ្ជើញរបស់អនុប្រធាន តាមការប្រគល់សិទ្ធិរបស់ប្រធាន។

**មាត្រា៩.-**

គណៈកម្មាធិការលទ្ធកម្មមានភារកិច្ច ជាសារវន្ត ដូចខាងក្រោម÷

- ពិនិត្យនិងសម្រេចលើសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំ ដែលរៀបចំដោយអង្គភាពលទ្ធកម្ម មុននឹងដាក់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យនិងអនុម័ត
- ត្រួតពិនិត្យនិងណែនាំ អង្គភាពលទ្ធកម្ម ឱ្យអនុវត្តតាមផែនការលទ្ធកម្ម ឱ្យបានត្រឹមត្រូវ
- ពិនិត្យ វាយតម្លៃ និងកំណត់បុរេលក្ខណសម្បត្តិ ចំពោះកិច្ចលទ្ធកម្មដែលមានលក្ខណៈស្មុគស្មាញ
- ពិនិត្យឡើងវិញលើទំហំទឹកប្រាក់នៃកញ្ចប់លទ្ធកម្មនីមួយៗ ដោយផ្ទៀងផ្ទាត់ជាមួយផែនការលទ្ធកម្ម មុននឹងចាប់ផ្តើមដំណើរការលទ្ធកម្ម
- ពិនិត្យនិងសម្រេច លើឯកសារដេញថ្លៃដែលស្ថិតក្នុងសិទ្ធិសម្រេចរបស់ខ្លួន ឬសម្រេចបញ្ជូនឯកសារដេញថ្លៃទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យនិងផ្តល់ទិដ្ឋាការ ចំពោះកិច្ចលទ្ធកម្មដែលត្រូវពិនិត្យនិងសម្រេចដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ប្រជុំបើកសំណើដេញថ្លៃ ពិគ្រោះថ្លៃ ស្ទង់តម្លៃ ឬ ចរចាថ្លៃ
- ប្រជុំវាយតម្លៃប្រគល់កិច្ចសន្យា
- ត្រួតពិនិត្យនិងវាយតម្លៃលើលក្ខណសម្បត្តិរបស់អ្នកដេញថ្លៃនាំមុខ មុនការសម្រេចប្រគល់កិច្ចសន្យា ឬបញ្ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យនិងសម្រេច ចំពោះកិច្ចលទ្ធកម្មដែលត្រូវពិនិត្យនិងសម្រេចដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅមុនការសម្រេចប្រគល់កិច្ចសន្យា
- ជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យាទៅអ្នកដេញថ្លៃឈ្នះ និងចម្លងជូនទៅគ្រប់អ្នកដេញថ្លៃចាញ់
- ផ្សព្វផ្សាយលទ្ធផលនៃការដេញថ្លៃជាសាធារណៈ

- គ្រប់គ្រង និងតាមដានការអនុវត្តកិច្ចសន្យា
- អញ្ជើញតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចូលរួមសង្កេតការណ៍គ្រប់ដំណាក់កាល នៃកិច្ចលទ្ធកម្មសាធារណៈ លើកលែងតែដំណាក់កាលនៃការវាយតម្លៃប្រគល់កិច្ចសន្យា
- ពិនិត្យនិងដោះស្រាយបណ្តឹងពាក់ព័ន្ធកិច្ចលទ្ធកម្ម តាមសមត្ថកិច្ចរបស់ខ្លួន
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំត្រីមាស ឆមាស និងឆ្នាំ ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៣

## អង្គភាពលទ្ធកម្ម

**មាត្រា១០.-**

គ្រប់ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវបង្កើតអង្គភាពលទ្ធកម្មមួយ ដោយប្រកាស សេចក្តីសម្រេច ឬដីកា ដែលមានរចនាសម្ព័ន្ធច្បាស់លាស់និងមានមន្ត្រីមានសមត្ថភាពជំនាញផ្នែកលទ្ធកម្មសាធារណៈគ្រប់គ្រាន់ ព្រមទាំងមានសិទ្ធិអំណាចសមស្រប ដើម្បីទទួលខុសត្រូវអនុវត្តរាល់កិច្ចលទ្ធកម្មសាធារណៈ។

អង្គភាពលទ្ធកម្មមានរចនាសម្ព័ន្ធស្ថិតក្រោមប្រធានស្ថាប័នផ្ទាល់ និងជាលេខាធិការដ្ឋានរបស់គណៈកម្មាធិការលទ្ធកម្ម។

សម្រាប់សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត ការបង្កើតអង្គភាពលទ្ធកម្ម ត្រូវធ្វើឡើងដោយអង្គភាពប្រតិបត្តិ ដោយមានការអនុម័តយល់ព្រមពីក្រុមប្រឹក្សាភិបាល។

**មាត្រា១១.-**

អង្គភាពលទ្ធកម្ម ត្រូវដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានចំនួនពីររូបយ៉ាងច្រើនជាជំនួយការ។ ប្រធានអង្គភាពលទ្ធកម្ម មិនត្រូវមានតួនាទី និងភារកិច្ចពាក់ព័ន្ធនឹងកិច្ចការហិរញ្ញវត្ថុផ្សេងទៀតក្នុងស្ថាប័នរបស់ខ្លួនឡើយ។

ចំពោះស្ថាប័នអនុវត្តលទ្ធកម្ម ដែលជាក្រសួង ស្ថាប័ន ប្រធានអង្គភាពលទ្ធកម្ម មានឋានៈស្មើអនុប្រធាននាយកដ្ឋាន។

ចំពោះស្ថាប័នអនុវត្តលទ្ធកម្ម ដែលជាសហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត ប្រធានអង្គភាពលទ្ធកម្មមានឋានៈក្រោមអនុប្រធាននាយកដ្ឋាន តាមការកំណត់របស់ក្រុមប្រឹក្សាភិបាល។

**មាត្រា១២.-**

ប្រធានអង្គភាពលទ្ធកម្ម ត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម៖

- មានកម្រិតវប្បធម៌មិនតិចជាងបរិញ្ញាបត្រផ្នែកសេដ្ឋកិច្ច ឬផ្នែកហិរញ្ញវត្ថុ
- មានបទពិសោធន៍ការងារផ្នែកសេដ្ឋកិច្ច ឬផ្នែកហិរញ្ញវត្ថុយ៉ាងតិច ៣ឆ្នាំ
- ធ្លាប់បានឆ្លងកាត់វគ្គបណ្តុះបណ្តាលផ្នែកលទ្ធកម្មសាធារណៈ ដោយមានវិញ្ញាបនប័ត្របញ្ជាក់ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៣.-**

អង្គភាពលទ្ធកម្ម បំពេញមុខងារជាលេខាធិការដ្ឋានរបស់គណៈកម្មាធិការលទ្ធកម្ម ដោយមានភារកិច្ច ជាសារវន្តដូចខាងក្រោម៖

- រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ និង/ឬផែនការលទ្ធកម្មកែតម្រូវក្នុងករណីចាំបាច់

- រៀបចំឯកសារដេញថ្លៃ សម្រាប់ប្រភេទលទ្ធកម្មនីមួយៗ ផ្អែកតាមគំរូឯកសារដេញថ្លៃដែលកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រៀបចំ និងផ្សព្វផ្សាយសេចក្ដីជូនដំណឹងអំពីការដេញថ្លៃ
- លក់ ឬផ្ដល់ឯកសារដេញថ្លៃជូនអ្នកមានបំណងចូលរួមក្នុងការដេញថ្លៃ
- ទទួលសំណើដេញថ្លៃ និងបកស្រាយបំភ្លឺចំពោះអ្នកដេញថ្លៃ ក្នុងករណីមានសំណួរពាក់ព័ន្ធនឹងការដេញថ្លៃ
- រៀបចំនិងគ្រប់គ្រងសំណើដេញថ្លៃ រួមទាំងឯកសារពាក់ព័ន្ធដែលបានទទួល ប្រកបដោយភាពត្រឹមត្រូវ សុវត្ថិភាព មុនពេលបើកសំណើដេញថ្លៃ
- ចាត់ចែងនិងរៀបចំទីកន្លែងសម្រាប់បើកសំណើដេញថ្លៃ
- រៀបចំបើកសំណើដេញថ្លៃជាសាធារណៈ ដោយមានការត្រួតពិនិត្យពីគណៈកម្មាធិការលទ្ធកម្ម
- រៀបចំរបាយការណ៍ឬកំណត់ហេតុស្ដីពីការបើកសំណើដេញថ្លៃ ពិគ្រោះថ្លៃ ស្នងតម្លៃ ឬចរចាថ្លៃ
- សម្របសម្រួលការវាយតម្លៃលើលក្ខណៈបច្ចេកទេសនៃសំណើដេញថ្លៃ
- ឆ្លើយតបចំពោះសំណួរពាក់ព័ន្ធនឹងរបាយការណ៍វាយតម្លៃលើសំណើដេញថ្លៃ
- រៀបចំលិខិតជូនដំណឹងស្ដីពីការប្រគល់កិច្ចសន្យា ដល់អ្នកដេញថ្លៃឈ្នះ និងចម្លងជូនអ្នកដេញថ្លៃចាញ់ទាំងអស់
- រៀបចំការផ្សព្វផ្សាយលទ្ធផលនៃការដេញថ្លៃ
- រៀបចំសេចក្ដីព្រាងកិច្ចសន្យាដោយអនុលោមតាមបទដ្ឋាន និងគំរូកិច្ចសន្យាដែលកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- តាមដានការអនុវត្តកិច្ចសន្យា ដោយសហការជាមួយមន្ត្រីបច្ចេកទេស និងមន្ត្រីជំនាញពាក់ព័ន្ធផ្សេងទៀត
- តាមដានការទូទាត់តម្លៃកិច្ចសន្យាជូនអ្នកផ្គត់ផ្គង់ អ្នកទទួលការ ឬទីប្រឹក្សា
- រៀបចំរបាយការណ៍ស្ដីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំត្រីមាស ឆមាស និងឆ្នាំ។

## ជំពូកទី៤

## បទប្បញ្ញត្តិដោយឡែក

**មាត្រា១៤.-**

នីតិវិធីនៃការបង្កើត ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៥.-**

នីតិវិធីនៃការបង្កើត ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលឃុំ សង្កាត់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៦.-**

នីតិវិធីនៃការបង្កើត ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់ដៃគូឯកជនសាធារណៈ ត្រូវកំណត់ដោយឡែក ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៥

## អន្តរប្បញ្ញត្តិ

**មាត្រា១៧.-**

នៅពេលមិនទាន់មានប្រកាសអន្តរក្រសួង រវាងក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចមានចែងក្នុងមាត្រា១៥ ខាងលើ នីតិវិធីនៃការបង្កើត ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលឃុំ សង្កាត់ ត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធជាធរមាន។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា១៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ